# Office of Immigrant and Refugee Affairs (ការិយាល័យអន្តោប្រវេសន៍ និងកិច្ចការជនភៀសខ្លួន)

Office of Immigrant and Refugee Affairs (OIRA, ការិយាល័យអន្តោប្រវេសន៍ និងកិច្ចការជនភៀសខ្លួន) ទីក្រុង Seattle បានខិតខំបំពេញការងារដើម្បីលើកកម្ពស់ជីវិតរស់នៅនៃអ្នកស្នាក់នៅក្នុងនាមជាជនអន្តោប្រវេសន៍និងជនភៀសខ្លួនក្នុងទីក្រុង Seattle។ តាមរយៈ New Citizen Campaign (យុទ្ធនាការពលរដ្ឋថ្មី)របស់ខ្លួន, OIRA ខិតខំធ្វើយ៉ាងដើម្បីឲ្យជនអន្តោប្រវេសន៍និងជនភៀសខ្លួនបានក្លាយជាពលរដ្ឋពេញលេញ និងអាចចូលរួមក្នុងសហគមន៍របស់ពួកគេបានកាន់ច្រើន។

វគ្គអប់រំអំពីសញ្ជាតិនេះ ទទួលបានការឧបត្ថម្ភដោយ Office of Immigrant and Refugee Affairs (ការិយាល័យអន្តោប្រវេសន៍ និងកិច្ចការជនភៀសខ្លួន) ដោយមានការសហការជាមួយអង្គការនានានៅតាមសហគមន៍។

- Asian Counseling and Referral Service
- Catholic Immigration Legal Services
- Chinese Information and Service Center
- Entre Hermanos
- Horn of Africa Services
- International Rescue Committee
- Korean Community Service Center
- OneAmerica
- Refugee Women's Alliance
- Somali Family Safety Task Force
- South Park Information and Resource Center
- The West African Community Council




# ទទួលបានជំនួយដោយឥតគិតថ្លៃសម្រាប់ការដាក់ពាក្យសុំសញ្ជាតិ អាមេរិក!



## វគ្គអប់រំអំពីសញ្ជាតិ ឥតគិតថ្លៃ ទទួលបានការឧបត្ថម្ភពី Asian Counseling and Referral Service និង West African Community Council។

ក្រុមមេធាវីអ្នកស្ម័គ្រចិត្ត ជំនួយការមេធាវី និងអ្នកបកប្រែផ្ទាល់មាត់នឹងជួយអ្នកក្នុងការដាក់ពាក្យសុំសញ្ជាតិរបស់អ្នក។ ពុំមានការគិតថ្លៃនោះទេសម្រាប់អ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់ (អ្នកកាន់បណ្ណបៃតង)។

October 5, 2019 SATURDAY
Start time: 10 AM

ASIAN COUNSELING AND REFERRAL SERVICE (ACRS)
3639 Martin Luther King Jr Way S
Seattle, WA  98144

**Seattle**
Office of Immigrant and Refugee Affairs

ចុះឈ្មោះសម្រាប់កំណត់ពេលវេលា ដោយទូរស័ព្ទទៅលេខ៖ (206) 805-8981. ។ សម្រាប់ព័ត៌មានបន្ថែមអំពីការដាក់ពាក្យស្នើសុំសញ្ជាតិ សូមចូលទៅកាន៖ newcitizencampaign.org.

# សិទ្ធិទទួលបាន

ដើម្បីមានសិទ្ធិទទួលបានការដាក់ពាក្យសុំសញ្ជាតិអាមេរិក អ្នកត្រូវ៖

- □ មានអាយុយ៉ាងតិច 18 ឆ្នាំ គិតត្រឹមថ្ងៃដែលអ្នកដាក់ពាក្យសុំ។
- □ ជាអ្នកស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់យ៉ាងតិច 5 ឆ្នាំ (ឬ 3 ឆ្នាំ ប្រសិនបើបានរៀបការជាមួយពលរដ្ឋអាមេរិក)។
- □ មានវត្តមានរស់នៅសហរដ្ឋអាមេរិកយ៉ាងតិច 2.5 ឆ្នាំ ក្នុងរយៈពេល 5 ឆ្នាំចុងក្រោយ (ឬ 1.5 ឆ្នាំ ក្នុងរយៈពេល 3 ឆ្នាំចុងក្រោយ ប្រសិនបើបានរៀបការជាមួយពលរដ្ឋអាមេរិក)។
- □ អាចនិយាយភាសាអង់គ្លេសកម្រិតមូលដ្ឋានបាន (អ្នកអាចមានលក្ខណៈគ្រប់គ្រាន់ទទួលបានការលើកលែងណាមួយ)។

# អ្វីដែលត្រូវយកមកជាមួយ

- □ ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍របស់អ្នក (ប័ណ្ណបៃតង)។
- □ លិខិតប្រកាសបង់ប្រាក់ពន្ធចុងក្រោយបំផុតរបស់អ្នក និងទម្រង់ W-2 ។
- □ លិខិតឆ្លងដែនបច្ចុប្បន្ន និងលិខិតឆ្លងដែនផុតសុពលភាពទាំងអស់របស់អ្នក។
- □ ឯកសារទាំងអស់ដែលអ្នកមានពាក់ព័ន្ធនឹងកំណត់ត្រាអន្តោប្រវេសន៍របស់អ្នក។
- □ ថ្លៃសេវាដាក់ពាក្យសុំ - ខុសគ្នាទៅតាមកម្រិតប្រាក់ចំណូល៖

ថ្លៃសេវាពេញលេញគឺ $725។

ប្រសិនបើអ្នកមានគម្រោងចង់បង់ថ្លៃពាក្យសុំដោយខ្លួនឯង អ្នកនឹងត្រូវមានមូលប្បទានបត្រ, មូលបុត្រទានបត្របៃឡាករ, ឬលិខិតបង្គាប់បង់ប្រាក់ ដែលត្រូវទូទាត់ទៅ "U.S. Department of Homeland Security (ក្រសួងសន្តិសុខមាតុភូមិសហរដ្ឋអាមេរិក)។"

អ្នកអាចមានលក្ខណៈសម្បត្តិទទួលបានការអនុគ្រោះលើថ្លៃសេវា ឬទទួលបានការបញ្ចុះតម្លៃ។ ដើម្បីត្រួតពិនិត្យសិទ្ធិទទួលបានរបស់អ្នក អ្នកត្រូវយកមកជាមួយនូវ៖

ភស្តុតាងបញ្ជាក់ពី Department of Social and Health Services (DSHS, នាយកដ្ឋានសេវាសង្គម និងសេវាសុខាភិបាល) អំពីអត្ថប្រយោជន៍សាធារណៈនានា ដូចជាលិខិតអនុញ្ញាតផ្តល់អត្ថប្រយោជន៍ ឬ

ភស្តុតាងបញ្ជាក់ប្រាក់ចំណូល ឧទាហរណ៍ លិខិតប្រកាសបង់ប្រាក់ពន្ធចុងក្រោយបំផុតរបស់អ្នក និងគល់បញ្ជីបង់ប្រាក់។

# ឯកសារបន្ថែម

អ្នកនឹងត្រូវប្រមូលព័ត៌មានដូចខាងក្រោម៖

- □ បញ្ជីអាសយដ្ឋានលំនៅដ្ឋានក្នុងរយៈពេល 5 ឆ្នាំចុងក្រោយ និងកាលបរិច្ឆេទក្នុងអំឡុងពេលដែលអ្នករស់នៅក្នុងអាសយដ្ឋានទាំងនេះ។
- □ បញ្ជីឈ្មោះ និងអាសយដ្ឋានក្រុមហ៊ុនក្នុងរយៈពេល 5 ឆ្នាំចុងក្រោយ និងកាលបរិច្ឆេទដែលអ្នកធ្វើការនៅក្នុងក្រុមហ៊ុនទាំងនេះ។
- □ កាលបរិច្ឆេទដែលអ្នកស្ថិតនៅក្រៅសហរដ្ឋអាមេរិក ចាប់តាំងពីបានក្លាយខ្លួនជាអ្នកស្នាក់នៅអចិន្ត្រៃយ៍ និងបណ្តាប្រទេសនានាដែលអ្នកបានធ្វើដំណើរក្នុងអំឡុងដំណើរកម្សាន្តទាំងនេះ។
- □ ឈ្មោះពេញ និងថ្ងៃខែឆ្នាំកំណើតកូនរបស់អ្នក និងលេខចុះបញ្ជីជាជនបរទេសរបស់ពួកគេ ប្រសិនបើមាន។
- □ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត កាលបរិច្ឆេទរៀបអាពាហ៍ពិពាហ៍ និងកាលបរិច្ឆេទលែងលះនៃប្តីឬប្រពន្ធបច្ចុប្បន្ននិងពីមុនទាំងអស់។

អ្នកក៏ត្រូវការឯកសារបន្ថែមទាំងនេះផងដែរ៖

- □ សំបុត្រអាពាហ៍ពិពាហ៍។
- □ ដីកាលែងលះ។
- □ ភស្តុតាងបញ្ជាក់ពីការជួយផ្គត់ផ្គង់ដល់កូនក្នុងបន្ទុករបស់អ្នក។
- □ ឯកសារបញ្ជាក់ពីការផ្លាស់ប្តូរឈ្មោះជាផ្លូវការ (ប្រសិនបើឈ្មោះនៅលើប័ណ្ណបៃតងខុសគ្នាពីឈ្មោះផ្លូវការបច្ចុប្បន្នរបស់អ្នក)។
- □ ប្រសិនបើអ្នកកំពុងដាក់ពាក្យសុំផ្អែកទៅតាមការរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋអាមេរិក សូមយកមកជាមួយនូវឯកសារបញ្ជាក់សញ្ជាតិអាមេរិករបស់ប្តីឬប្រពន្ធរបស់អ្នក (ឧទាហរណ៍ លិខិតឆ្លងដែន លិខិតបញ្ជាក់ការចូលសញ្ជាតិ ឬសំបុត្រកំណើតអាមេរិក) និងឯកសារនានាដែលបញ្ជាក់ថាអ្នករស់នៅជាមួយគ្នា (ឧទាហរណ៍ វិក្កយបត្រសេវាសាធារណៈ ដែលបញ្ជាក់ថាអ្នកទាំងពីររស់នៅក្នុងលំនៅដ្ឋានជាមួយគ្នា)។
- □ ប្រសិនបើអ្នកធ្លាប់ត្រូវបានគេចាប់ខ្លួន ឬឃុំខ្លួនដោយមន្ត្រីអនុវត្តច្បាប់ដោយមូលហេតុណាមួយ សូមយកមកជាមួយនូវ Certificate of Disposition (លិខិតបញ្ជាក់ការសម្រេចទោស) ពី តុលាការព្រហ្មទណ្ឌសំណៅថតចម្លងមួយច្បាប់នៃលិខិតបញ្ជាក់ឥរិយាមាយាទពីមន្ត្រីនគរបាល និងឯកសារផ្សេងទៀតដែលអ្នកមានអំពីហេតុការណ៍ណាមួយ។

អាចស្វែងរកអ្នកបកប្រែផ្ទាល់មាត់បាន ប៉ុន្តែពេលវេលារង់ចាំអាចខ្លីជាងមុន ប្រសិនបើអ្នកនាំយកអ្នកបកប្រែផ្ទាល់ខ្លួនមក។